**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខៈ ..០៨៧/២៣...........អអរ**

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តពោធិ៍សាត់"

នាព្រឹកថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តពោធិ៍សាត់»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម ខូយ រីដា អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តពោធិ៍សាត់**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តពោធិ៍សាត់ ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តពោធិ៍សាត់ មានប្រជាពលរដ្ឋរស់នៅសរុប ៥២០.៧៥២នាក់ ស្មើនឹង ១៣២.៨៥៥គ្រួសារ ដែលបែងចែកចេញជា ក្រុង១ ស្រុក៦ ឃុំ៤២ សង្កាត់៧ និង៥២៦ភូមិ។ ប្រជាពលរដ្ឋទូទាំងខេត្តប្រកបរបរកសិកម្ម ៧១,៦០% សេវាកម្ម ១៨,៧០% ពាណិជ្ជកម្ម ៥,៨០% សិប្បករ ០,៧០% និងជាមន្ត្រីរាជការ ៣,២០% ដោយទំហំសេដ្ឋកិច្ចខេត្ត មានចំនួនប្រមាណ ៧៣៤,១ លានដុល្លារអាមេរិក ស្មើនឹង ៣,៧% នៃសេដ្ឋកិច្ចជាតិ ដែល GDP សម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំមានចំនួនប្រមាណ ១.៤៣៧ដុល្លារអាមេរិក អត្រាភាពក្រីក្រធ្លាក់ចុះមកត្រឹម ១២,៧០% នៅក្នុងឆ្នាំ២០២២នេះ។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដោយឧបត្ថម្ភជូនគ្រួសារក្រីក្រសរុប ២៨.០៦០គ្រួសារ អស់ថវិកា ១៥២.១៨០.៣៨០.០០០រៀល, ជូនស្ត្រីមានផ្ទៃពោះ ៥.៣៣៧នាក់ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួន ១.៩០៧នាក់ អស់ថវិកា ៣.៩៩០.៥៦០.០០០រៀល, ជូនគ្រួសារងាយរងហានិភ័យដោយគ្រោះទឹកជំនន់ និងសម្ពាធអតិផរណាសរុប ៤.៧៣១គ្រួសារ អស់ថវិកា ៦៣៩.៣៥៤.១០០រៀល។ ជាមួយគ្នានេះ ចំពោះជីវភាពគ្រួសារអតីតយុទ្ធជន ក៏ត្រូវបានលើកកម្ពស់ ដោយមាននូវគម្រោងថវិកាជានារ៉ាប់រងសង្គមជូនដល់អតីតយុទ្ធជន ព្រមទាំងបានផ្តល់ដី និងផ្ទះជូនបងប្អូនអតីតយុទ្ធជន និងគ្រួសារសរុបចំនួន ៦២៨ ខ្នងផ្ទះផងដែរ។
- **វិស័យកសិកម្ម៖** ជាវិស័យដែលទ្រទ្រង់សេដ្ឋកិច្ចខេត្តចម្បង ខេត្តមានផ្ទៃដីផលិតកម្មដំណាំស្រូវសរុបប្រមាណ ១៧៤.៤៨៥ ហិកតា ជារៀងរាល់ឆ្នាំ ដែលទទួលបានទិន្នផលជាមធ្យមប្រមាណ ៤តោនក្នុងមួយហិកតា, ដំណាំឧស្សាហកម្ម សរុបចំនួន ៤៩.៩៣៧ ហិកតា ទទួលបានបរិមាណផលសរុបប្រមាណ ៦៣៧.៦៦៤ តោន ក្នុងមួយឆ្នាំ, ដំណាំសាកវប្បកម្មសរុបប្រចាំឆ្នាំជាមធ្យមសរុបប្រមាណ ១.៥៧០ ហិកតា ដែលទទួលបានបរិមាណផលសរុប ១៩.៦៦២ តោន និងផ្ទៃដីដំណាំឈើហូបផ្លែចំនួន ១២.៣២៥ហិកតា ដែលទទួលបានបរិមាណផលប្រមាណ ២០៥.៧៧៥តោន។ ទន្ទឹមនឹងសក្តានុពលទិន្នផលទាំងអស់នេះ រដ្ឋបាលខេត្តក៏បានខិតខំជំរុញការផ្សព្វផ្សាយបច្ចេកទេសដាំដុះ ការប្រើប្រាស់ថ្នាំ ជីគីមី ព្រមទាំងជំរុញនូវការដាំដំណាំសុវត្ថិភាព (មិនប្រើប្រាស់ថ្នាំ និងជីគីមី) តាមរយៈការបង្កើតឱ្យមានសហគមន៍កសិកម្ម ចំនួន ៦០សហគមន៍ និងក្រុមបណ្តុំកសិករធ្វើអាជីកម្មកសិកម្មចំនួន ៧៤បណ្តុំ ក្នុងន័យបង្កើនប្រាក់ចំណូលនៅតាមតំបន់ និងធានាបាននូវសន្តិសុខស្បៀងអាហារផងដែរ។
- **ការងារសុរិយោដី៖** ទូទាំងខេត្ត បានផ្តល់ប័ណ្ណជូនប្រជាពលរដ្ឋចំនួន ២០៦.៦២០ក្បាលដី ការងារចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ បានបញ្ចូលទិន្នន័យក្បាលដី ចំនួន ១០៧.៨២៨ក្បាលដី កំពុងបិទផ្សាយជាសាធារណៈចំនួន ៨២.១៦៨ក្បាលដី និងបានចែកប័ណ្ណជូនប្រជាពលរដ្ឋ ចំនួន ៥៨.៣១០ប័ណ្ណ ក្នុងនោះដីរដ្ឋដែលបានចុះបញ្ជីរួចមានចំនួន ១៤៤ក្បាលដី ព្រមទាំងបានយកចិត្ត ទុកដាក់រៀបចំកែសម្រួលផ្ទៃដីតំបន់១ តំបន់២ តំបន់៣ នៃបឹងទន្លេសាប និង

សហការរៀបចំកែសម្រួលព្រំនៃតំបន់ការពារធនធានធម្មជាតិ ដើម្បីផ្ដល់សិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ អាស្រ័យផលជាក់ស្ដែង និងពិតប្រាកដ។

- **វិស័យទេសចរណ៍៖** តាមរយៈរមណីយដ្ឋានទេសចរណ៍ធម្មជាតិ តំបន់អេកូទេសចរណ៍ តំបន់ភ្នំព្រៃឈើខៀវស្រងាត់ មានផ្ទៃទឹក បឹង ស្ទឹង ជ្រលង ដងអូរ គួរឱ្យគយគន់ អាកាសធាតុត្រជាក់ និងតំបន់ចម្ការហូបផ្លែនានា សុទ្ធសឹងតែជាសក្ដានុពលទ្រទ្រង់ និងអំណោយផលដល់ការងារទេសចរណ៍ ដោយខេត្តទទួលបានភ្ញៀវទេសចរសរុបចំនួន ៣.៩១០.១៤៩នាក់ ក្នុងនោះភ្ញៀវទេសចរអន្តរជាតិចំនួន ២៧.៥០៣នាក់។
- **ការងារសន្តិសុខ សណ្ដាប់ធ្នាប់ និងការផ្ដល់សេវាសាធារណៈ៖** រដ្ឋបាលខេត្តយកចិត្តទុកដាក់ពង្រឹងគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រុង ស្រុក និងអាជ្ញាធរឃុំ សង្កាត់ជាប្រចាំ ធ្វើឱ្យបទល្មើសគ្រប់ប្រភេទមានការថយចុះគួរឱ្យកត់សម្គាល់ ជាពិសេស បទល្មើសគ្រឿងញៀនថយចុះ ១២០លើក ជាមួយគ្នានេះ កិច្ចសហប្រតិបត្តិការជាមួយខេត្តត្រាត នៃព្រះរាជាណាចក្រថៃមានលក្ខណៈល្អប្រសើរ ទាំងការងារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន ការទប់ស្កាត់បទល្មើសឆ្លងដែន និងជំងឺឆ្លងនានា។ ចំពោះការផ្ដល់សេវាសាធារណៈ តាមរយៈយន្តការច្រកចេញ-ចូលតែមួយត្រូវបានពង្រឹង និងពង្រីកដល់មូលដ្ឋានឃុំ-សង្កាត់ ទៅលើ ១៤វិស័យ ដែលយន្តការនេះ បានបង្វិតសេវាឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ ហើយនីតិវិធីមានលក្ខណៈសាមញ្ញ ឆាប់រហ័ស តម្លាភាព គណនេយ្យភាព ភាពជឿទុកចិត្តបាន និងគ្មានអំពើពុករលួយ។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត បានអនុវត្តនូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយបានសម្របសម្រួល ដោះស្រាយពាក្យបណ្ដឹង បញ្ហាប្រឈម សំណូមពរ និងវិវាទផ្សេងៗជូនប្រជាពលរដ្ឋបានសរុបចំនួន ៦,៨៦៧ករណី។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** ដោយប្រើប្រាស់ថវិការដ្ឋបាលខេត្ត ថវិកាមូលនិធិរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងមានការសហការជាមួយមន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្ត ហេដ្ឋារចនាសម្ព័ន្ធទូទាំងខេត្ត មានការរីកចម្រើនគួរកត់សម្គាល់ ក្នុងនោះហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ បង្គោលភ្លើងបំភ្លឺផ្លូវ ប្រឡាយទឹក ទំនប់ទឹក ប្រព័ន្ធលូរំដោះទឹកជាដើមដែលជាតម្រូវការចាំបាច់នៅមូលដ្ឋាន ត្រូវបានពង្រីក និងតភ្ជាប់គ្រប់ខេត្ត ក្រុង ស្រុក ទីប្រជុំជន ទីជនបទ និងតំបន់ដាច់ស្រយាល។ ជាក់ស្ដែង បណ្ដាញផ្លូវជាតិ និងផ្លូវខេត្តមានចំនួន ៥៥ខ្សែ ប្រវែងសរុប ១.០៩៨,២៩គីឡូម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម ៨៣ខ្សែ ប្រវែង ៣១២,៥០គីឡូម៉ែត្រ ផ្លូវលំ ៣២៣ខ្សែ ប្រវែង ៣១០,៩៥គីឡូម៉ែត្រ។ ជាមួយគ្នានេះ ការងារអភិវឌ្ឍន៍ជនបទ ក៏ត្រូវបានលើកកម្ពស់ ជាពិសេស បណ្ដាញផ្គត់ផ្គង់ទឹកស្អាត បានគ្របដណ្ដប់ចំនួន ៨០%។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្តពោធិ៍សាត់ បានប្តេជ្ញាចិត្តនឹងបន្តខិតខំធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ខេត្ត ដើម្បីលើកកម្ពស់សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន បន្តពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជំរុញការអភិវឌ្ឍជាបន្តបន្ទាប់លើគ្រប់វិស័យ ពិសេសជំរុញការផ្គត់ផ្គង់បណ្តាញអគ្គិសនី និងទឹកស្អាតឱ្យបាន ១០០%។ បន្តពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយខេត្តត្រាត នៃព្រះរាជាណាចក្រថៃ ដើម្បីឱ្យព្រំដែននៃប្រទេសទាំងពីរ ក្លាយទៅជាព្រំដែនមិត្តភាព សន្តិភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍ ពិសេសជំរុញការបើកច្រកទ្វារព្រំដែនអន្តរជាតិ ថ្មដា-បានថាសេន ជាផ្លូវការឱ្យបានឆាប់។ ជាមួយគ្នានេះ បន្តយកចិត្តទុកដាក់ និងកែលម្អជាបន្តបន្ទាប់ លើការងារសង្គមកិច្ច ដើម្បីលើកកម្ពស់សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋ តាមរយៈការជំរុញវិស័យសុខាភិបាល និងវិស័យពាក់ព័ន្ធនានា បន្តពង្រឹងការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ធានាបាននូវការបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរ ព្រមទាំងជំរុញការរៀបចំវេទិកាសាធារណៈ នៅតាមភូមិនីមួយៗទូទាំងខេត្ត ដើម្បីស្វែងយល់ និងទទួលយកនូវបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន សំដៅធ្វើការដោះស្រាយ និងឆ្លើយតបឱ្យបានទាន់ពេលវេលា៕

ថ្ងៃអង្គារ ១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣